# ភ្លូងលម្អជំនួសផេះ ៖ គន្លងព្យាបាលនៃការអភ័យទោស



អស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំបានខិតខំស្វែករកភាពសុខសាន្ត និងការព្យាបាលនៅលើគន្លងនៃការអភ័យទោស ហើយខ្ញុំបានដឹងនៅក្នុងរបៀបដ៏ជ្រាលជ្រៅមួយថា ព្រះរាជបុត្រានៃព្រះដែលបានធួននឹងអំពើបាបរបស់ខ្ញុំ គឺជាព្រះអង្គសង្គ្រោះដដែល ដែលនឹងសង្គ្រោះអ្នកដែលបានធ្វើឲ្យខ្ញុំឈឺចាប់យ៉ាងខ្លាំង ។ ខ្ញុំអាចជឿលើសេចក្ដីពិតទីមួយហើយក៏ត្រូវជឿលើសេចក្ដីពិតទីពីរដែរ ។

នៅពេលដែលសេចក្ដីស្រឡាញ់របស់ខ្ញុំមានសម្រាប់ព្រះអង្គសង្គ្រោះបានកើនឡើង ដូច្នេះខ្ញុំក៏ប្រាថ្នាចង់ឲ្យអំណាចដ៏ប្រោសលោះរបស់ទ្រង់ព្យាបាលការឈឺចាប់ និងកំហឹងរបស់ខ្ញុំ ។ វាគឺជាដំណើរការមួយដែលមានរយៈពេលជាច្រើនឆ្នាំ ដែលទាមទារឲ្យមានភាពក្លាហាន ភាពងាយរងគ្រោះ ការតស៊ូ និងការរៀនដាក់ទីទុកចិត្តទៅលើអំណាចដ៏ទេវភាពរបស់ព្រះអង្គសង្គ្រោះ ដើម្បីសង្គ្រោះ និងព្យាបាល ។ ខ្ញុំនៅតែមានកិច្ចការដែលត្រូវធ្វើ ប៉ុន្តែដួងចិត្តរបស់ខ្ញុំលែងខឹងក្រោធចងគំនុំទៀតហើយ ។ ខ្ញុំត្រូវបានប្រទានឲ្យមាន « ចិត្តថ្មី » [ អេសេគាល ៣៦:២៦ ]—ចិត្តមួយដែលមានអារម្មណ៍ស្រឡាញ់ផ្ទាល់ខ្លួនដ៏ជ្រាលជ្រៅ និងស្ថិតស្ថេររបស់ព្រះអង្គសង្គ្រោះ ដែលទ្រង់បានគង់នៅក្បែរខ្ញុំ ដឹកនាំខ្ញុំទៅកាន់កន្លែងដែលប្រពៃដោយទន់ភ្លន់ និងអត់ធ្មត់ ដែលបានទួញសោកជាមួយខ្ញុំ ហើយជ្រាបពីទុក្ខព្រួយរបស់ខ្ញុំ ។ . . .

អែលឌើរ រីឆាដ ជី ស្កុត បានមានប្រសាសន៍ ៖ « បងប្អូនមិនអាចលុបចោលរឿងដែលបានកើតឡើងរួចហើយបានទេ ប៉ុន្តែបងប្អូនអាចអភ័យទោសបាន ។ ការអភ័យទោសផ្សះផ្សាស្នាមរបួសដ៏ឈឺចាប់ខ្លោចផ្សា ព្រោះវាអនុញ្ញាតឲ្យសេចក្ដីស្រឡាញ់នៃព្រះសម្អាតដួងចិត្ត និងគំនិតដែលពុលដោយសារចិត្តស្អប់របស់បងប្អូន ។ វាលាងសម្អាតសតិសម្បជញ្ញៈរបស់បងប្អូនចេញពីបំណងចង់សងសឹក ។ វាផ្ដល់កន្លែងសម្រាប់ការបន្សុទ្ធ ការព្យាបាល និងការស្ដារឡើងវិញនូវសេចក្ដីស្រឡាញ់របស់ព្រះអម្ចាស់ » [ « Healing the Tragic Scars of Abuse » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩២ ទំព័រ ៣៣ ] ។

ឪពុកនៅលើផែនដីរបស់ខ្ញុំក៏បានផ្លាស់ប្ដូរនៅក្នុងដួងចិត្តប្រកបដោយអព្ភូតហេតុផងដែរនៅប៉ុន្មានឆ្នាំនេះ ហើយបានបែរទៅរកព្រះអម្ចាស់—ជាអ្វីមួយដែលខ្ញុំនឹកស្មានមិនដល់ទាល់តែសោះក្នុងជីវិតនេះ ។ នេះជាទីបន្ទាល់មួយទៀតរបស់ខ្ញុំអំពីអំណាចដ៏ពេញលេញ និងផ្លាស់ប្ដូររបស់ព្រះយេស៊ូវគ្រីស្ទ ។

ខ្ញុំដឹងថា ទ្រង់អាចព្យាបាលមនុស្សមានបាប និងអស់អ្នកដែលបានប្រព្រឹត្តអំពើបាបទាស់នឹងពួកគេបាន ។ ទ្រង់គឺជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះនៃពិភពលោកនេះ ដែលបានលះបង់ព្រះជន្មរបស់ទ្រង់ ដើម្បីយើងអាចរស់ម្ដងទៀតបាន ។ ទ្រង់មានបន្ទូលថា « ព្រះវិញ្ញាណព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ពីព្រោះទ្រង់បានចាក់ប្រេងតាំងខ្ញុំឲ្យផ្សាយដំណឹងល្អដល់មនុស្សទ័លក្រ ទ្រង់បានចាត់ខ្ញុំឲ្យមកដើម្បីនឹង *ប្រោសមនុស្សដែលមានចិត្តសង្រេង* ហើយប្រកាសប្រាប់ពីសេចក្ដីប្រោសលោះដល់ពួកឈ្លើយ និងសេចក្ដីភ្លឺឡើងវិញដល់មនុស្សខ្វាក់ហើយឲ្យ*ដោះមនុស្សដែលត្រូវគេជិះជាន់ឲ្យរួច* » [ លូកា ៤:១៨ បានបន្ថែមការគូសបញ្ជាក់ ] ។

ទ្រង់ប្រទានការព្យាបាល ការជាសះស្បើយ និងការរំដោះ ដល់អស់អ្នកណាដែលមានចិត្តសង្រេង ជាប់ឃុំឃាំង ត្រូវគេជិះជាន់ និងប្រហែលជាខ្វាក់ ដោយសារតែការឈឺចាប់ ឬអំពើបាប ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ការព្យាបាល និងការជាសះស្បើយដែលទ្រង់ប្រទានឲ្យគឺមានពិតមែន ។ ពេលវេលានៃការជាសះស្បើយគឺរៀងៗខ្លួន ហើយយើងមិនអាចវិនិច្ឆ័យពេលវេលារបស់អ្នកដទៃបានទេ ។ វាជាការសំខាន់ក្នុងការអនុញ្ញាតឲ្យខ្លួនឯងមានពេលវេលាចាំបាច់ដើម្បីជាសះស្បើយ និងមានចិត្តល្អចំពោះខ្លួនឯងនៅក្នុងដំណើរការនៃការព្យាបាលនេះ ។ ព្រះអង្គសង្គ្រោះតែងតែមានព្រះទ័យមេត្តាករុណា និងយកចិត្តទុកដាក់ជានិច្ច ហើយត្រៀមព្រះកាយរួចជាស្រេចដើម្បីប្រទានជំនួយដែលយើងត្រូវការ ។

នៅលើគន្លងនៃការអភ័យទោស និងការព្យាបាល មានជម្រើសមួយដើម្បីកុំបន្តធ្វើតាមគន្លង ឬទំនាក់ទំនងមិនល្អនោះនៅក្នុងក្រុមគ្រួសាររបស់យើង ឬនៅកន្លែងផ្សេងទៀត ។ យើងអាចមានសន្ដានចិត្តល្អជាការឆ្លើយតបនឹងភាពឃោរឃៅ សេចក្ដីស្រឡាញ់ជាការឆ្លើយតបនឹងការស្អប់ ភាពទន់ភ្លន់ជាការឆ្លើយតបនឹងភាពគំរោះគំរោយ សុវត្ថិភាពជាការឆ្លើយតបនឹងទុក្ខព្រួយ ហើយសេចក្ដីសុខសាន្តជាការឆ្លើយតបនឹងជម្លោះ ទាំងអស់នេះគឺស្ថិតនៅក្រោមឥទ្ធិពលរបស់យើង ។

ការផ្ដល់នូវអ្វីដែលបងប្អូនមិនបានទទួល គឺជាផ្នែកមួយដ៏មានឥទ្ធិពលនៃការព្យាបាលដ៏ទេវភាព ដែលអាចទទួលបានតាមរយៈសេចក្ដីជំនឿនៅលើព្រះយេស៊ូវគ្រីស្ទ ។ ការរស់នៅក្នុងរបៀបមួយដែលបងប្អូនផ្ដល់ឲ្យនូវភួងលម្អជំនួសផេះនៃជីវិតរបស់បងប្អូន ដូចជាអេសាយបានមានប្រសាសន៍ [ សូមមើល អេសាយ ៦១:៣ ] គឺជាសកម្មភាពនៃសេចក្ដីជំនឿដែលដើរតាមគំរូដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គសង្គ្រោះ ដែលបានរងទុក្ខគ្រប់យ៉ាងដើម្បីទ្រង់អាចជួយដល់យើងតាមជម្ងឺរបស់យើង ។ . . .

ខ្ញុំសូមថ្លែងទីបន្ទាល់ថា គំរូដ៏អស្ចារ្យនៃសេចក្ដីស្រឡាញ់ និងការអភ័យទោសគឺមកពីព្រះអង្គសង្គ្រោះរបស់យើង គឺព្រះយេស៊ូវគ្រីស្ទ ដែលបានមានបន្ទូលទាំងឈឺចាប់ខ្លាំងថា « ឱព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ដ្បិតគេមិនដឹងជាគេធ្វើអ្វីទេ » [ លូកា ២៣:៣៤ ] ។ ( គ្រីស្ទីន អិម យី « ភួងលម្អជំនួសផេះ ៖ គន្លងព្យាបាលនៃការអភ័យទោស » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០២២ ទំព័រ ៣៧–៣៨ )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២៤ by Intellectual Reserve, Inc. All rights reserved. PD80007812_258_262-1